**Best Start Kindergarten Assessment**
**Information for parents and carers**

# ការវាយតម្លៃលើការចាប់ផ្តើមចូលសាលាមត្តេយ្យបានល្អបំផុត

## ព័ត៌មានសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ

ជូនចំពោះឪពុកម្តាយ និងអ្នកថែទាំ

ការវាយតម្លៃលើការចាប់ផ្តើមចូលសាលាមត្តេយ្យបានល្អបំផុត នឹងប្រព្រឹត្តទៅនៅសាលារៀនរបស់យើង នៅឆមាសទី 1។

ការវាយតម្លៃលើការចាប់ផ្តើមចូលសាលាមត្តេយ្យបានល្អបំផុត គឺជាការវាយតម្លៃទូទាំងរដ្ឋ ដែលជួយបង្ហាញគ្រូបង្រៀនអំពីជំនាញអក្ខរកម្ម និងការចេះរាប់លេខរបស់សិស្សម្នាក់ៗនៅពេលចាប់ផ្តើមសាលាមត្តេយ្យ។ ការនេះជួយឱ្យគ្រូបង្រៀនរៀបចំផែនការមេរៀនដើម្បីជួយទ្រទ្រង់ដល់តម្រូវការសិក្សារបស់កុមារគ្រប់រូបបានល្អបំផុត។

កុមារចូលសាលារៀនដោយមានបទពិសោធន៍ ជំនាញ និងសមត្ថភាពជាច្រើន។ ខ្លះស្គាល់សៀវភៅ អាចសម្គាល់ដឹងតួរអក្ខរ ឬថែមទាំងចេះសរសេរឈ្មោះរបស់ពួកគេ ឬរាប់ដល់ដប់ទៀតផង ខណៈកុមារឯទៀតមិនទាន់ទាំងបានរៀនជំនាញទាំងនេះនៅឡើយ។

ការវាយតម្លៃលើការចាប់ផ្តើមចូលសាលាមត្តេយ្យបានល្អបំផុត ផ្តល់ឱ្យគ្រូបង្រៀននូវឱកាសដើម្បីអង្គុយជាមួយកុមារម្នាក់ៗដោយផ្តោតលើអ្វីដែលកុមារអាចធ្វើបាន។

ការវាយតម្លៃមិនមែនជាការធ្វើតេស្តទេ ប៉ុន្តែផ្តល់ឱ្យគ្រូបង្រៀននូវព័ត៌មានដ៏មានប្រយោជន៍ ដើម្បីជួយដល់ការរៀនសូត្ររបស់កូនលោកអ្នកនៅឯសាលារៀន។ ប្រសិនបើលោកអ្នកប្រាថ្នាចង់ដកកូនរបស់លោកអ្នក ចេញពីការចូលរួមក្នុងការវាយតម្លៃនេះ សូមទាក់ទងមកសាលារៀន។

សន្លឹកព័ត៌មានដែលភ្ជាប់មកជាមួយនេះ នឹងផ្តល់ជូនព័ត៌មានបន្ថែមអំពីការវាយតម្លៃលើការចាប់ផ្តើមចូលសាលាមត្តេយ្យបានល្អបំផុត។

សូមទាក់ទងមកសាលារៀន ប្រសិនបើលោកអ្នកមានសំណួរណាមួយទាក់ទិននឹងការវាយតម្លៃលើការចាប់ផ្តើមចូលសាលាមត្តេយ្យបានល្អបំផុត។

## សេវាអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយលោកអ្នកទាក់ទងមកសាលារៀន សូមទូរស័ព្ទទៅសេវាអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់លោកអ្នក។ អ្នកបកប្រែភាសានឹងហៅទូរស័ព្ទទៅសាលារៀន ហើយនឹងបន្តនៅតាមទូរស័ព្ទដើម្បីជួយនៅក្នុងការសន្ទនា។ លោកអ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវានេះទេ។

នាយកសាលា